**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រិតការ នៃក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការប្រែក្លាយសាលាភូមិន្ទនគរបាលទៅជាបណ្ឌិត្យសភានគរបាលកម្ពុជា
- តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានកែសម្រួលនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រិតការ បច្ចុប្បន្នចំណុះអគ្គស្នងការដ្ឋាននគរបាលជាតិ ទៅជានាយកដ្ឋានបណ្តុះបណ្តាលចំណុះបណ្ឌិត្យសភានគរបាលកម្ពុជានៃក្រសួងមហាផ្ទៃ ។

**មាត្រា២ :** នាយកដ្ឋានបណ្តុះបណ្តាលនៃបណ្ឌិត្យសភានគរបាលកម្ពុជា មានភារកិច្ចដូចខាងក្រោម :

- ពិចារណា លើកទិសដៅ កសាងផែនការបណ្តុះបណ្តាល និងវិក្រិតការនៅតាមសាលានគរបាលជាតិចំណុះនាយកដ្ឋានបណ្តុះបណ្តាល
- ចាត់តាំង អនុវត្តផែនការបណ្តុះបណ្តាល តាមកម្មវិធីរបស់បណ្ឌិត្យសភានគរបាលកម្ពុជា នៃក្រសួងមហាផ្ទៃ
- ស្រាវជ្រាវ និងរៀបចំចងក្រងឯកសារសិក្សា ការបង្ហាត់បង្រៀន និងគ្រប់គ្រងគ្រូឧទ្ទេស ដើម្បីដំណើរការងារបណ្តុះបណ្តាលអោយបានល្អប្រសើរ

www.pheakdeylaw.com

- គ្រប់គ្រងសាលានគរបាលជាតិក្រោមឱវាទនាយកដ្ឋាន
- ធ្វើអធិការកិច្ចសិក្សា និងរៀបចំវិញ្ញាសារប្រឡងគ្រប់វគ្គសិក្សានៅតាមសាលានគរបាលជាតិក្រោមឱវាទនាយកដ្ឋាន
- សិក្សាស្រាវជ្រាវ ធ្វើទំនើបភាវូបនីយកម្មខ្លឹមសារឯកសារបង្ហាត់បង្រៀន កម្មវិធីសិក្សា និងកម្មសិក្សាប្រតិបត្តិ
- ចេញវិញ្ញាបនបត្របញ្ជាក់ការសិក្សាជូនកម្មសិក្សាការីដែលបានបញ្ចប់កម្មសិក្សាដោយជោគជ័យ
- រៀបចំគំរោងផែនការថវិការ សំភារៈបរិក្ខា មធ្យោបាយ សំរាប់បំរើការងារបណ្តុះបណ្តាលនៅតាមសាលានគរបាលជាតិក្រោមឱវាទនាយកដ្ឋាន
- ធ្វើការបូកសរុប ដកពិសោធន៍អំពីខ្លឹមសារ កម្មវិធីសិក្សា វិធីសាស្ត្រក្នុងការបង្រៀនក្រោយពេលបញ្ចប់វគ្គនីមួយៗ ដើម្បីរាយការណ៍ជូនបណ្ឌិត្យសភានគរបាលកម្ពុជា មានវិធានការកែលំអសំរាប់វគ្គក្រោយៗទៀត
- ធ្វើការងាររដ្ឋបាល បុគ្គលិក ភស្តុភារ គណនេយ្យរបស់នាយកដ្ឋាន តាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃប្រគល់អោយ ។

**មាត្រា៣** : នាយកដ្ឋានបណ្តុះបណ្តាល ដឹកនាំដោយប្រធានមួយនាក់ និងមានអនុប្រធានមួយចំនួនជាជំនួយ ។

**មាត្រា៤** : នាយកដ្ឋានបណ្តុះបណ្តាលមានការិយាល័យជំនាញ និងសាលានគរបាលជាតិមួយចំនួនចំណុះ ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងសាលានគរបាលជាតិចំណុះនាយកដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា៥** : បណ្ឌិត្យសភានគរបាលកម្ពុជាត្រូវសម្របសម្រួល និងសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយកដ្ឋានបណ្តុះបណ្តាល និងនាយកដ្ឋានបុគ្គលិកធ្វើជាសេនាធិការ ដើម្បីកសាងផែនការបណ្តុះបណ្តាល និងរៀកិតការដល់មន្ត្រីនគរបាលជាតិ តាមដំណាក់កាលនីមួយៗអោយបានល្អប្រសើរ ។

**មាត្រា៦** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា៧** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ.ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៩*




**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*__កន្លែងទទួល__*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៧*
- *ឯកសារ-កាលប្បវត្តិ* ✓

www.pheakdeylaw.com